101 8th Street, Suite 100
Oakland, CA 94607

## សារពីលោកស្រី Sherry Hirota នាយកប្រតិបត្តិ



សួស្តីអ្នកជំងឺរបស់មន្ទីរព្យាបាលអាស៊ីជាទីស្រលាញ់
តើអ្នកសុខសប្បាយជាទេ? ខ្ញុំចង់ជំរាបអ្នកថាមន្ទីរព្យាបាលអាស៊ីនៅទីនេះសំរាប់អ្នក។
យើងបើកទទួលការថែទាំតាមរយៈការណាត់ជួបដោយផ្ទាល់, តាមវីដេអូ ឬតាមទូរស័ព្ទ។
ម្យ៉ាងទៀតយើងទើបនឹងបង្កើតខ្សែទូរស័ព្ទសំរាប់ឆ្លើយនឹងសំណួរផ្សេងៗ៥១០_៧៣៥_៣២២២។
ក្រុមជំនាញរួមមាន វេជ្ជបណ្ឌិតផ្នែកវេជ្ជសាស្ត្រ, ទន្តបណ្ឌិត, អ្នកជំនាញខាងចិត្តសាស្ត្រ រង់ចាំជួយអ្នក
ថែមទាំងចាត់វិធានការបន្ថែមសំរាប់ការពារអ្នក បុគ្គលិកយើង និងសហគមន៍។ ការអប់រំសុខភាពដែលអាចទុកចិត្តបាន,
ការធានារ៉ាប់រង និងការប្រឹក្សាពីការបញ្ចុះតំលៃសេវា, ការយល់ពីភាពតានតឹងនិងការភ័យខ្លាចរបស់អ្នក,
ព៌តមានស្តីពីជំនួយបន្ទាន់ និងសំបុត្របញ្ជូន ទាំងឡាយជាភាសារបស់អ្នក។ យើងរង់ចាំអ្នកទាក់ទងមកយើងវិញ
តាមទូរស័ព្ទ តាមអ៊ីនធ័រណែត ឬជួបផ្ទាល់មុខតែម្តង។ យើងសូមអរគុណដែលអ្នកមានទំនុកចិត្តលើមន្ទីរព្យាបាលអាស៊ី។
យើងបើកទ្វារសំរាប់បំរើលោកអ្នក។

Thank you,

Sherry Hirota
*Chief Executive Officer*

# ASIAN HEALTH SERVICES
NEWSLETTER
**SPRING 2020**

## សារលិខិតពីវេជ្ជបណ្ឌិត ចច លី, ប្រធានផ្នែកវេជ្ជសាស្ត្រនៃមន្ទីរព្យាបាល




(Photo of Dr. George Lee courtesy of Sing Tao)

ខ្ញុំដឹងថានេះជាគ្រាលំបាកសំរាប់អ្នកជំងឺនិងសហគមន៍
យើង។ក្នុងកំលុងពេលជំងឺរាតត្បាតកូវីដ១៩
មន្ទីរព្យាបាលអាស៊ីនៅតែបើកទ្វារដើម្បីបំរើសេចក្តីត្រូវការរបស់អ្នក។
យើងបានពង្រីកទៅជាការព្យាបាលតាមទូរស័ព្ទ
គឺអ្នកអាចនិយាយជាមួយគ្រូពេទ្យតាមទូរស័ព្ទ និងវីដេអូ។

ប្រសិនជាអ្នកត្រូវបានណែនាំដោយគ្រូពេទ្យរបស់អ្នកឲ្យមកជួបដោយផ្ទាល់
សូមធ្វើតាមការបញ្ជានេះ។ ពេលដែលអ្នកមកកាន់ទីតាំងរបស់យើង
ការការពារសុខភាព និងសុវត្ថិភាពរបស់អ្នកគឺជាអាទិភាពចំបងរបស់យើង។
យើងបានបង្កើតនូវប្រព័ន្ធការពារជាច្រើនដំណាក់ដើម្បីការពារអ្នកជំងឺ
និងបុគ្គលិក ដូចជាការវាស់សីតុណ្ហភាព,តំរូវឲ្យគ្រប់គ្នាដែលចូល
ក្នុងអាគារពាក់ម៉ាស់មុខ,ដាក់អ្នកជំងឺណាដែលនឹង
ត្រូវធ្វើតេស្តដាច់ដោយឡែកពីគេឯង
និងធ្វើការសំអាតជាច្រើនដងក្នុងមួយថ្ងៃ។

ដូចដែលយើងបានធ្វើ៤៦ឆ្នាំកន្លងមកហើយ
មន្ទីរព្យាបាលអាស៊ីនិងបុគ្គលិកយើងនៅតែ
ប្តេជ្ញាចិត្តដើម្បីបំរើអ្នកជំងឺចំរុះជាតិសាសន៍ និងសហគមន៍
របស់យើងជាមួយផ្នែកវេជ្ជសាស្ត្រ,ទន្តសាស្ត្រ និងផ្នែកសុខភាពផ្លូវចិត្ត។

## បណ្តាញជំនួយកូវីដ១៩
### បណ្ឌិតជូខូត៍ អនុប្រធានរដ្ឋបាល

នៅមន្ទីរព្យាបាលអាស៊ីយើងទទួលស្គាល់ថាតំរូវការរបស់
សង្គមដូចជាភាពអត់ការងារធ្វើ,ការទទួលបានអាហារ,ការស្នាក់នៅ,
ការធ្វើអន្តោប្រវេសន៍ស្របច្បាប់និងការធានារ៉ាប់រង
សុខភាពគឺជាការចាំបាច់សំរាប់សុខភាព។ ឥលូវនេះយើងមាន
បណ្តាញជំនួយកូវីដ១៩ដែលជាបុគ្គលិកពេទ្យសហគមន៍
ដែលបានទទួលការបណ្តុះបណ្តាលហើយអាចជួយអ្នកក្នុងការ
ដោះស្រាយតំរូវការផ្សេងៗ។




101 8th Street, Suite 100, Oakland, CA 94607

ASIAN HEALTH SERVICES
HEALTH CARE FOR ALL. ADVOCACY FOR THE UNDERSERVED.

មន្ទីរព្យាបាលអាស៊ីបានបើកដំណើរការ ហើយមានផ្តល់ជូនចំពោះតំរូវការផ្នែកសុខភាពរបស់អ្នកក្នុងកំលុងពេលរោគកូវីដ១៩, តាមរយៈការជួបតាមទូរស័ព្ទ!



# តើការជួបតាមទូរស័ព្ទដំណើរការយ៉ាងដូចម្តេច?



1) សូមទូរស័ព្ទមកយើងដើម្បីកំណត់ការណាត់ជួបតាមទូរស័ព្ទរបស់អ្នក



2) អ្នកផ្តលសេវាផ្នែកវេជ្ជសាស្ត្រនឹងទូរស័ព្ទទៅអ្នកតាមម៉ោងកំណត់ដើម្បីពិភាក្សាពីបញ្ហាសុខភាពដូចខាងក្រោម៖



សំណួរ ឬ រោគសញ្ញាណាមួយដែលទាក់ទងនឹងរោគកូវីដ១៩



សេចក្តីត្រូវការការថែទាំបន្ទាន់



ការថែទាំរោគរ៉ាំរ៉ៃប្រចាំកាយ



ការសុំបំពេញថ្នាំបន្ថែម



យើងកម្រិតចំនួនអ្នកជំងឺមកជួបនៅក្នុងមន្ទីរព្យាបាលយើងនៅពេលនេះដើម្បីកាត់បន្ថយការឆ្លងរាលដាលនៃជំងឺកូវីដ១៩។ គ្រូពេទ្យអ្នកជាអ្នកសំរេចចិត្តថាតើអ្នកត្រូវមកជួបផ្ទាល់មុខឬទេ បន្ទាប់ពីគាត់បានជួបអ្នកតាមទូរស័ព្ទរួច។

បើអ្នកមានធានារ៉ាប់រងឬគ្មានយើងនឹងសហការជាមួយអ្នកដោយមិនទាក់ទងនឹងលទ្ធភាពនៃការបង់ប្រាក់របស់អ្នកឬអត់។ ម៉្យាងទៀតប្រសិនជាអ្នកមានសិទ្ធិទទួលធានារ៉ាប់រងយើងចង់ជួយអ្នកក្នុងការចុះឈ្មោះ,ឬបំពេញឯកសារឡើងវិញ សំរាប់ទុកបង្ការក្រែងអ្នកឈឺនៅពេលអនាគត។

asianhealthservices.org



## ការទទួលយកអ្នកជំងឺថ្មី និងការដាក់ពាក្យសុំសេវាសុខភាព

មន្ទីរព្យាបាលអាស៊ីបើកទទួល និងផ្តល់ជូនការបំរើសេវាសុខភាពតាមសេចក្តីត្រូវការរបស់អ្នកក្នុងកំលុងពេលកូវីដ១៩! ក្នុងកំលុងពេលនេះ,យើងនឹងបន្តទទួលអ្នកជំងឺថ្មី! បើស្ថានភាពហិរញ្ញវត្ថុរបស់អ្នកមានការប្រែប្រួល យើងក៏អាចជួយអ្នកដាក់ពាក្យសុំសេវាសុខភាពដោយផ្អែកលើស្ថានភាពថ្មីរបស់អ្នក។ សូមទាក់ទងផ្នែកសេវាសមាជិកលេខ៥១០-៩៨៦-៦៨៨០។

## ការព្យាបាលដោយមិនគិតថ្លៃក្នុងកំលុងពេលនៃការរាតត្បាតរោគកូវីដ១៩

ការថែទាំរបស់អ្នកនឹងមិនគិតថ្លៃទេក្នុងកំលុងពេលនៃការរាតត្បាតពីជំងឺកូវីដ ទោះជាអ្នកមានធានារ៉ាប់រងសុខភាព ឬគ្មាន។ បើអ្នកមានធានារ៉ាប់រង យើងប្រហែលជាអាចនឹងលើកលែងថ្លៃចំណែកដែលអ្នកត្រូវបង់, ម្យ៉ាងទៀតប្រសិនជាអ្នកមានសិទ្ធិទទួលធានារ៉ាប់រងយើងចង់ជួយអ្នកក្នុងការចុះឈ្មោះ ទុកបង្ការក្រែងអ្នកឈឺនៅពេលអនាគត។